## វគ្គទី៤

# ម្លប់សន្តិភាព

(បទពាក្យប្រាំពីរ)

១១០ - ផ្មេចបើកបើកផ្មេច ភ្លេចត្រចៀក
វេលាដើរកៀក ក្រៀកកើតកើន
អរុណោទ័យ ថ្មីក្រវើន
ពន្លឺប្រាលច្រើន ជះរស្មី ។

១១១ - ទេព្តាកម្តៅ ក្តៅចែងចាំង
បញ្ចេញកម្លាំង ខ្លាំងវិថី
ស្រោចស្រពស្រស់ស្រាយ ចាយជាថ្មី
បំភ្លឺផែនដី ចាស់ខ្លោចផ្សា ។

១១២ - ឆ្នាំកៅប្រាំបី ស្ដីចូលដល់
ស្រុកអំណោយផល ផ្ដល់វាសនា
ម្លប់សន្តិភាព ជ្រាបរដ្ឋា
ជួបជុំចរចា ការងារជាតិ ។

១១៣ - **ឈ្នះ ឈ្នះ** ជម្នះ នយោបាយ
យុទ្ធសាស្ត្រស្រាយ កាយខ្មីឃ្មាត
ប្រជុំប្រជួប រួបរួមជាតុ
សង្សឹមព្រោងព្រាត ឃ្លាតទុក្ខភ័យ ។

១១៤ - សមាហរណកម្មចូលគ្នា
ដំបៅសះជា ទារជោគជ័យ
បង្រួបបង្រួម ខ្មែរគ្រប់វ័យ
វេញផ្គុំប្រពៃ ឈាមតែមួយ ។

១១៥ - ក្រុមខ្មែរក្រហម អមអ៊ូអរ
កកកុញកុះករ លែងផ្តល់ព្រួយ
ចាកចេញពីព្រៃ លៃបោះពួយ
ចុះចូលលើកស្ទួយ ជួយរដ្ឋា ។

១១៦ - ទម្លាក់អាវុធ ពត់ដួងចិត្ត
ស្រឡាញ់អាណិត ជាតិខេមរា
កំហឹងកំហុស ខុសម្តេចម្តា
លើកលែងបេ្តជ្ញា អនុគ្រោះ ។

១១៧ - ប្រជាសប្បាយ កាយសម្បូរ
ទឹកភ្នែកស្រក់ហូរ ដោររង្គោះ
រំភើយរំភើប ពើបពីរោះ
សុបិនហោះផ្លោះ ក្លាយការពិត ។

១១៨ - សង្គ្រាមស៊ីវិល រលីងរលៃ
ចប់បរាជ័យ លៃលកគិត
សន្តិភាពពេញ វេញគំនិត
គំនរជីវិត រីតសប្បាយ ។

១១៩ - គ្រួសារ **សុផល** ខ្វល់បាត់សូន្យ
ប្រពន្ធនិងកូន ក្បូនឆើតឆាយ
**មាលា** សង្ឃឹម ផ្ទឹមចិត្តកាយ
ស្រុកភូមិជិតឆ្ងាយ ក្លាយជាមិត្ត ។

១២០ - ម្ចប់សន្តិភាព ជ្រាបពេញទី
ខ្មែររួមមូលមីរ ស្នេហ៍ជាតិពិត
ស្តារស្តាប់ស្តីស្តែង តែងតែគិត
នាវាជីវិត រីតល្បីល្បឿន ។

១២១ - ជឿជាក់ជោគជ័យ លៃលកប្រឹង
ប្រជាសម្លឹង ថ្លឹងដាស់តឿន
ជម្រកជំរំ ជុំជំរឿន
សេដ្ឋកិច្ចលឿន លាន់សុសសាយ ។

១២២ - រៀបចំរៀបចិត្ត រៀបចិន្តា
កសាងរដ្ឋា ការត្រួសត្រាយ
ត្រង់ត្រាប់ត្រឹមត្រូវ ផ្លូវសប្បាយ
សម្បូរឆើតឆាយ ស្រាយស្រស់ថ្លា ។

១២៣ - ជិតស្នាមញញឹម សង្ឃឹមកើត
កំណាប់កំណើត អើតសង្ខា
ខ្មែរមួយប្រទេស បេះពិចារ
ទុក្ខមរណា បាក់ខ្លបខ្លាច ។

១២៤ - ខ្មែររួបខ្មែររួម ខ្មែររីកខ្លាំង
សង្គ្រាមតតាំង អស់អំណាច
មានសន្តិភាព ជ្រាបអង់អាច
ចិត្តសាហាវកាច បានបាត់បង់ ។

១២៥ - **សុផល** ញញឹម ផ្ទឹមមិនបាន
ទឹកភ្នែកជ្រែកប្រាន ស្រាន្តផ្លូវផង់
ចិត្តជាយោធា ទារតម្រង់
ចំណានចំណង់ ចង់បានសុខ ។
១២៦ - លះបង់បូជា វេលាច្រើន
ចម្រុងចម្រើន កើនស្រណុក
សាច់ស្រស់ ឈាមស្រស់ អស់ក្តួលក្តុក
បានឃើញភូមិស្រុក ផុតទុក្ខា ។
១២៧ - បេះដូងទឹកចិត្ត បិតថៃទាំ
មោះមុតមួនមាំ ទ្រាំវាសនា
ដង្ហើមដង្ហោយ ឱ្យខេមរា
ថ្នមថែរក្សា កុំឱ្យឃ្លាត ។
១២៨ - ត្បិតសន្តិភាព ជ្រាបបានមក
លះបង់លែលក រកខ្នីឃ្នាត
ដើមទុនជីវិត មិត្តរួមជាតិ
តស៊ូព្រោងព្រាត ឆ្ងៀតពលី ។

១២៩- ប្រទេសប្រទីប ទ្វីបលោកា
លោកីយ៍ថ្លៃថ្លា ចារវក់រី
ស្រេកឃ្លានខ្លាំងណាស់ ច្បាស់សំគី
សន្តិគ្រប់ទី រស់រុងរឿង ។

១៣០- សន្តិភាពនាំ មាំជំហរ
ជំហានឈានឈរ សាទរសឿង
លូតគ្រប់វិស័យ ច្នៃគ្រប់គ្រឿង
ផ្ទះថ្មតដ្ឋក្បឿង កើនកាក់កប ។

១៣១- សន្ទៀមសុខសាន្ត បានផ្សព្វផ្សាយ
សម្បូរសប្បាយ កាយចិត្តស្រប
មាំមួនមូលមីរ ទីសម្រប
រប៉ាំងរបប អបលូតលាស់ ។

១៣២- ជាតិខ្មែរប្រែមុខ ទុក្ខរសាយ
រសាត់ខ្ចាត់ខ្ចាយ ឆ្ងាយទំនាស់
ទំនាក់ទំនង ចងជាឃ្នាស់
សប្បាយកាយគាស់ រាស់រុករាន ។

១៣៣ - ពន្លកពន្លឺ ភ្លឺគំរូ
រដ្ឋាគិតគូរ ស៊ូដូចស្ពាន
ចម្លងចម្លាក់ ធ្លាក់ជាយាន
បណ្ដុះធនធាន គ្មានត្អូញត្អែរ ។

១៣៤ - កិច្ចការទាក់ទង ចងខ្មីឃ្មាត
អន្តរជាតិ ឆ្ងៀតហូរហែ
ខឿនសេដ្ឋកិច្ច ច្បិចពូកែ
ចាប់ផ្ដើមស្គាល់ខ្មែរ ថែស្នេហ៍ស្និទ្ធ ។

១៣៥ - វិនិយោគទុន លើសលន់លឿន
ល្បីល្បាញថែមល្បឿន តឿនខំខិត
ទាំងក្នុងនិងក្រៅ ដៅដាមជិត
ស្រឡាញ់អាណិត ចិត្តជួយខ្មែរ ។

១៣៦ - រដ្ឋាភិបាល ថ្នាលថ្នមថ្នាក់
ស្រាយឧបសគ្គ ស្រាក់ពូកែ
ស្ដារស្ដាប់លើកស្ទួយ ជួយហូរហែ
សង្ឃឹមប្រួលប្រែ ថែមុខមាត់ ។

១៣៧ - កសាងការពារ ជាប្រចាំ
បណ្ដុះផ្សៀមផ្សាំ ដាំធំធាត់
គិតគូរស្មោះស្ម័គ្រ អភិវឌ្ឍ
ស្ទុះស្ទាស្ទួយស្ទាត់ រាល់ខែថ្ងៃ ។

១៣៨ - ព្រះអាទិត្យថ្មី សម័យឆ្នើម
សុខសាន្តសន្សៀម ផ្ដើមកែច្នៃ
ពន្លឺបាចសាច អាចស្រមៃ
ស្រមោលតម្លៃ ល្បីគ្មានផ្ទឹម ។

១៣៩ - **មាលា សុផល** និង **ធាក៉**
ទាំងបីរូបា ចារញញឹម
សន្តិភាពមាំ នាំសង្ឃឹម
ព្រលប់ព្រលឹម រៀនធ្វើការ ។

១៤០ - ការកិច្ចថ្មី ស្ដីសុខសាន្ត
ប្រជាសន្តាន បានសុខា
ក្រោមម្លប់ដឹកនាំ មាំចិន្តា
គ្រប់គ្រងរដ្ឋា ស្នេហាជាតិ ។